# សិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយដាក់បន្ទុកខ្លួនឯង

(Right to Non Self-Incrimination)

## ១. សេចក្តីផ្តើម

នៅក្នុងដំណើរការក្តីព្រហ្មទណ្ឌ ជនសង្ស័យ មានសិទ្ធិសេរីភាពជាច្រើន ក្នុងនោះមានសិទ្ធិ មិនត្រូវបង្ខំឲ្យឆ្លើយដាក់បន្ទុកខ្លួនឯង។ អត្ថិភាព ឬវិសាលភាពនៃសិទ្ធិនេះ មិនត្រូវបានដឹងជាទូទៅទេ ដោយសារក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានចែងដោយផ្ទាល់ និងមិនបានលម្អិតច្រើនទេ។ អត្ថបទ នឹងពិនិត្យមើលខ្លឹមសារ បទប្បញ្ញត្តិអន្តរជាតិ ដែលមានចែងនៅក្នុងច្បាប់ធម្មនុញ្ញរបស់ប្រទេសមួយចំនួន មុននឹងពិនិត្យមើលបទប្បញ្ញត្តិពាក់ព័ន្ធក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ជាចុងក្រោយ អត្ថបទនឹងផ្តល់ជាអនុសាសន៍មួយចំនួន។

## ២. សិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយដាក់បន្ទុក

### ២.១. មូលហេតុនៃអត្ថិភាពនៃសិទ្ធិនេះ

នៅក្នុងរឿងព្រហ្មទណ្ឌ ចៅក្រម ត្រូវការភស្តុតាង ដែលផ្អែកតាមភស្តុតាងនោះ នឹងសម្រេចសេចក្តីពាក់ព័ន្ធនឹងកិច្ចមួយចំនួន ដូចជាការសម្រេចលើកលែងចោទ ឬបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ចម្លើយសារភាព ថាបានប្រព្រឹត្ត ជាឯកសារមួយ ត្រូវបានយកទៅពិចារណា ថាតើមានតម្លៃជាភស្តុតាងដែរឬទេ? ក្នុងប្រវត្តិនៃយុត្តិធម៌ព្រហ្មទណ្ឌ ជនសង្ស័យ ត្រូវបានបង្ខំឲ្យឆ្លើយ ហើយចម្លើយប្រភេទនេះ ត្រូវបានប្រើជាទូទៅ ជាយូរមកហើយ ដោយសារ វាមានភាពងាយស្រួលក្នុងការទទួលបាន ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីស៊ើបអង្កេតស្មុគ្រស្មាញ និងអូសបន្លាយពេលវេលា។

ក្នុងន័យនេះ ប្រសិនបើ វាជាចម្លើយសារភាព ដោយគ្មានការបង្ខំ វាមិនជាបញ្ហាទេ។ ប្រទេសកុំមុនឡូ ប្រើប្រាស់យន្តការ guilty plead ដោយផ្អែកលើចម្លើយសារភាព ទោះបីខ្លឹមសារនៃចម្លើយ អាចមិនពិត ក៏ប៉ុន្តែវាបានបង្ហាញថា ជនសង្ស័យសារភាពថាបានប្រព្រឹត្ត ជាថ្នូរដោះដូរនឹងការបន្ថយបទចោទខ្លះ (counts) ជាដើម។ Guilty plead ត្រូវបានធ្វើឡើងក្នុងទម្រង់ជាកិច្ចព្រមព្រៀងរវាង ជនសង្ស័យ និងរដ្ឋអាជ្ញា ហើយនីតិវិធីមានភាពសាមញ្ញ ដែលតុលាការ ត្រូវពិនិត្យនិងសម្រេចបន្ថែម លើខ្លឹមសារនៃ

ការព្រមព្រៀងរបស់ជនសង្ស័យ ថាតើការព្រមព្រៀងពិតប្រាកដ គ្មានការបង្ខំ និងជនង្ស័យបានដឹងអំពីផលវិបាកនៃការព្រមព្រៀងឬទេ។[1]

អ្វីជាបញ្ហា គឺការបង្ខំឲ្យជនសង្ស័យឆ្លើយសារភាព ហើយយកចម្លើយនោះ ទៅចោទប្រកាន់នាពេលក្រោយ។ វាកាន់តែធ្ងន់ធ្ងរថែមទៀត ប្រសិនបើចម្លើយសារភាព ត្រូវបានធ្វើឡើងដោយការប្រើប្រាស់អំពើទារុណកម្ម ដែលជាទម្រង់បំពានលើរូបរាងកាយដ៏ធ្ងន់ធ្ងរមួយ។ វាអាចខុសនឹងគោលការណ៍សន្មតមិនទាន់មានទោសដរាបណាមិនទាន់មានទោសស្ថាពរ (presumption of innocence)[2] ដោយសារ ការធ្វើទារុណដូចនេះ ត្រូវបានគេសន្មតថា ជនត្រូវចោទ មានទោសរួចហើយ ទើបទទួលទោស ជាអំពើទារុណកម្ម។ វាក៏ពាក់ព័ន្ធផងដែរ នឹងសិទ្ធិមានមេធាវី ក្នុងអំឡុងពេលនៃការបង្ខំឲ្យឆ្លើយនោះ។ អាស្រ័យហេតុនេះ ផ្អែកតាមទ្រឹស្តីនៃការការពារសិទ្ធិមនុស្ស សន្ធិសញ្ញាសិទ្ធិមនុស្ស[3]ច្បាប់រដ្ឋធម្មនុញ្ញនៃបណ្តាប្រទេសជាច្រើនបានចែងនូវសិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយសារភាព ដែលសិទ្ធិប្រភេទនេះ មានឋានៈជាធម្មនុញ្ញ (constitutional rights) ជាតម្លៃចម្បង នឹងឈ្នះនូវសិទ្ធិផ្សេង ដែលផ្ទុយ បើតាមទ្រឹស្តីនៃឋានានុក្រមនៃសិទ្ធិ។

### ២.២. ខ្លឹមសារសិទ្ធិនៅក្នុងច្បាប់អន្តរជាតិ និង រដ្ឋធម្មនុញ្ញបរទេស

*មាត្រា ១៤ ចំណុចទី ៣(ឆ) មិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ*។[4] វាជាផ្នែកមួយនៃសិទ្ធិទទួលបានការកាត់សេចក្តីដោយយុត្តិធម៌។ វាមានពីរសមាសភាគៈ ទី១. ការមិនត្រូវបានបង្ខំឲ្យឆ្លើយថាខ្លួនឯងខុស។ ជនសង្ស័យ មិនត្រូវមានបន្ទុកដោះសារ ថាខ្លួនមិនបានប្រព្រឹត្តិទេ ដោយសារនេះជាបន្ទុកនៃភស្តុតាង ផ្ទុកផ្តាក់ទៅខាងអាជ្ញាធរចោទប្រកាន់។ បើដូចនេះមែន វាពិតជាមានភាពពាក់ព័ន្ធនិងបំពានគោលការណ៍សន្មតថាគ្មានទោសរហូតមានការសម្រេចសេចក្តីស្ថាពរ[5]។ ទី២. វា

---

[1] Amnesty International, Fair Trial Manual, 2nd ed., 2014, p. 130 (AI, Fair Trial).

[2] ច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ នៃកម្ពុជា មាត្រា ៣៨។

[3] មាត្រា ១៤(៣.ឆ) នៃកតិកាសញ្ញាស្តីពី សិទ្ធិប្រជាពលរដ្ឋ និងនយោបាយ។ មាត្រា ៤០(២.ខ.៤) នៃអនុសញ្ញា ស្តីពី សិទ្ធិកុមារ។ មាត្រា ១៨(៣.ឆ) នៃ អនុសញ្ញា ស្តីពី ការការពារសិទ្ធិពលករចំណាកស្រុក។ មាត្រា ៨(២.ឆ និង ៣) នៃអនុសញ្ញាអាមេរិក ស្តីពី សិទ្ធិមនុស្ស។ មាត្រា ១៦(៦) នៃ ធម្មនុញ្ញអារ៉ាប់។ គោលការណ៍២១ នៃគោលការណ៍ចម្បង ផ្នែក ន (៦)(យ) នៃគោលការណ៍ស្តីពី ការកាត់សេចក្តីដោយយុត្តិធម៌ នៃទ្វីបអាហ្វ្រិក។ មាត្រា ៦៧ (១.ឆ) នៃ លក្ខន្តិកៈស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ។ មាត្រា ២០(៤.ឆ) នៃលក្ខន្តិកៈស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិរ្វាន់ដា។ មាត្រា ២១ (៤.ឆ) នៃលក្ខន្តិកៈ ស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវី។

[4] កតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ ឆ្នាំ ១៩៦៧។

[5] AI, Fair Trial, *supra* note 1, p.129.

ពាក់ព័ន្ធ នូវសិទ្ធិរក្សាភាពស្ងៀមស្ងាត់។[6] ផ្នែកខាងក្រោមនឹងពិនិត្យមើលបទប្បញ្ញត្តិនៃបណ្ដាប្រទេសមួយចំនួន។

ខ្លឹមសារមានចម្រុះ ទាក់ទងនឹងដំណាក់កាល និង ប្រភេទនៃបុគ្គលជាម្ចាស់នៃសិទ្ធិនេះ៖ បុគ្គលស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេត[7] ជនត្រូវបានឃាត់ខ្លួន[8] ឬបុគ្គលទូទៅ ផ្ដើមដោយពាក្យ "*មិនមានបុគ្គលណាមួយត្រូវបាន...*"[9]។ ច្បាប់រដ្ឋធម្មនុញ្ញខ្លះ ចែងធានានូវសិទ្ធិនេះ ក្នុងអំឡុងពេលសវនាការ។[10] ច្បាប់រដ្ឋធម្មនុញ្ញខ្លះ ចែងធានានូវគ្រប់ដំណាក់កាលនៃនីតិវិធី។[11]

ការហាមឃាត់មិនប្រើចម្លើយសារភាព មិនគ្រាន់តែសម្រាប់ប្រឆាំងនឹងជនសង្ស័យខ្លួនឯងទេ ថែមទាំងមិនឲ្យយកទៅប្រើសម្រាប់ការចោទប្រកាន់លើសមាជិកគ្រួសារ របស់ជនសង្ស័យទៀតផង[12]។

---

[6] តុលាការសិទ្ធិអឺរ៉ុបថ្លែងថា៖ *សិទ្ធិរក្សាភាពស្ងៀមស្ងាត់ ក្នុងអំឡុងពេលការសួរចម្លើយដោយប៉ូលីស និងបុព្វសិទ្ធិប្រឆាំងនឹងការដាក់បន្ទុកខ្លួនឯង ជាស្តង់ដារអន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ដែលស្ថិតនៅជាចំណុចគន្លឹះ នៃសញ្ញាណនៃនីតិវិធីត្រឹមត្រូវ*'. European Court: *John Murray v United Kingdom* (18731/91), Grand Chamber (1996) §45, *Allan v United Kingdom* (48539/99), (2002) §44.

[7] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស the Philippines ឆ្នាំ ១៩៨៧, មាត្រា ១២(១)។

[8] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Ethiopia ឆ្នាំ ១៩៩៤, មាត្រា ១៩(២)។

[9] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Bahamas ឆ្នាំ ១៩៧៣, ផ្នែក២០(៧)៖ *មិនមានបុគ្គលណាមួយ ត្រូវបានវិនិច្ឆ័យសេចក្តីចំពោះបទល្មើសព្រហ្មទណ្ឌ ត្រូវបានបង្ខំឲ្យផ្តល់ភស្តុតាងនៅក្នុងអំឡុងពេលសវនាការទេ។*

[10] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Bahamas ឆ្នាំ ១៩៧៣, ផ្នែក ២០(៧)។ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Bangladesh ឆ្នាំ ២០១៤ មាត្រា ៣៥(៤)។ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Botswana ឆ្នាំ ២០១៦, ផ្នែក ១០(៧)។ ច្បាប់រដ្ឋធម្មនុញ្ញនៃ Barbados ឆ្នាំ ២០០៧ ផ្នែក ៧។ ច្បាប់រដ្ឋធម្មនុញ្ញនៃ Grenada ឆ្នាំ ១៩៩២ ផ្នែក៦(៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Guyana ឆ្នាំ ២០១៦ ផ្នែកទី១៤៤ (៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Kiribati ឆ្នាំ ២០១៣ ផ្នែកទី១០ (៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Malta ឆ្នាំ ២០១៦ ផ្នែក៣៩ (១០)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃMauritius ឆ្នាំ ២០១៦ ផ្នែកទី១០(៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Nauru ឆ្នាំ ២០១៥ ផ្នែកទី១០(៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Nigeria ឆ្នាំ ២០១៦ ផ្នែកទី ៣៦ (១១)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Saint Kitts and Nevis ឆ្នាំ ១៩៨៣ ផ្នែក ១០(៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Solomon ឆ្នាំ ២០១៨ ផ្នែកទី ១០(៧)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Tuvalu ឆ្នាំ ២០១០ ផ្នែកទី ២២ (១០)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃ Zambia ឆ្នាំ ២០១៦ មាត្រា ១៨(៧) ចែងថា៖ *មិនមាននរណាម្នាក់ ត្រូវបានវិនិច្ឆ័យសេចក្តី សម្រាបបទល្មើសព្រហ្មទណ្ឌ ត្រូវបានបង្ខំឲ្យផ្តល់ភស្តុតាងក្នុងពេលសវនាការទេ*។

[11] ដោយប្រើពាក្យ "*មិនមាននរណាម្នាក់.....*" ដោយមិនបញ្ជាក់នូវ ដំណាក់កាល ដូចនេះគេអាចនិយាយបានថា សិទ្ធិមិនត្រូវបង្ខំឲ្យដាក់បន្ទុកខ្លួនឯង មាននៅក្នុងគ្រប់ដំណាក់កាល, ច្បាប់រដ្ឋធម្មនុញ្ញនៃ Japan ឆ្នាំ ១៩៤៦ មាត្រា ៣៨។

[12] ច្បាប់រដ្ឋធម្មនុញ្ញរបស់ Chile ឆ្នាំ ២០១៨ មាត្រា ១៩(១០ច)។ ច្បាប់រដ្ឋធម្មនុញ្ញ នៃប្រទេស Colombia ឆ្នាំ ២០១៥ មាត្រា ៣៣ ចែងថា៖ *មិនមាននរណាម្នាក់អាចត្រូវបានបង្ខំឲ្យឆ្លើយ ប្រឆាំងនឹងខ្លួនឯង ឬប្តីប្រពន្ធ ដៃគូរយូរអង្វែង ឬញាតិលោហិត*

ជនសង្ស័យ ត្រូវបានជូនដំណឹងអំពីសិទ្ធិនៅស្ងៀម ជាមួយនឹងសិទ្ធិទទួលបានមេធាវីផងដែរ។[13] ទោះបីជាយ៉ាងនេះក្តី បទប្បញ្ញត្តិ មិនបានលម្អិតឲ្យដឹងថា ប្រសិនបើ គាត់ព្រមនិយាយ អ្វីដែលអះអាង នឹងយកទៅចោទប្រកាន់នាពេលខាងមុខ ឬក៏ប្រាប់ថា ជនសង្ស័យ អាចនិយាយនៅពេលមានវត្តមានរបស់មេធាវី។ យុត្តិសាស្ត្រណ្បីមួយ របស់តុលាការកំពូលសហព័ន្ធអាមេរិក ដែលនៅតែ ត្រូវបានប្រើប្រាស់នៅឡើយក្នុងរឿង miranda (*miranda warning*)។ តាមយុត្តិសាស្ត្រនេះ នៅពេលឃាត់ខ្លួន ប៉ូលីស ត្រូវប្រាប់អំពីសិទ្ធិមានមេធាវី និងរក្សាភាពស្ងៀមស្ងាត់មិនឆ្លើយ។ ជនសង្ស័យ អាចឆ្លើយ ឬមិនឆ្លើយ ដោយរង់ចាំមេធាវីសិន (ឆ្លើយជាមួយវត្តមាននៃមេធាវី) និងប្រាប់ថា បើសិនឆ្លើយ ចម្លើយនឹងត្រូវបានប្រើប្រាស់ក្នុងនីតិវិធីនាពេលខាងមុខ។ ប្រសិនបើ ប៉ូលីស មិនបានជូនដំណឹងឲ្យដឹងអំពីផលវិបាកនេះទេ ហើយយកចម្លើយ ចម្លើយនោះ អាចនឹងមិនត្រូវបានទទួលយកដោយតុលាការទេ។[14]

ក្នុងករណីមិនឆ្លើយ តើគេអាចទាញសន្និដ្ឋានបានដែរឬទេ? ច្បាប់រដ្ឋធម្មនុញ្ញភាគតិច និយាយដល់បញ្ហានេះ និងគ្រាន់តែចែងថា អាចនឹងទាញចេញនូវការសន្និដ្ឋានបាន។[15] ក៏ប៉ុន្តែ ការសន្និដ្ឋាន ថាជនបានប្រព្រឹត្ត ហើយការសន្និដ្ឋាននឹងទទួលយកដោយតុលាការដែរឬទេ នៅមានភាពមិនច្បាស់លាស់នៅឡើយ។ សិទ្ធិរក្សាភាពស្ងៀមស្ងាត់ អនុវត្តផងដែរ ក្នុងការចោទប្រកាន់បទឧក្រិដ្ឋធ្ងន់ធ្ងរ។ សម្រាប់ការទាញសន្និដ្ឋានពីភាពស្ងៀមស្ងាត់ ឯកសារអន្តរជាតិខ្លះ មិនអនុញ្ញាតឲ្យទាញសន្និដ្ឋាន នាំទៅរកពិរុទ្ធភាពទេ ក៏ប៉ុន្តែតុលាការសិទ្ធិមនុស្សអឺរ៉ុប មានជំហរបត់បែន អនុញ្ញាតឲ្យទាញការសន្និដ្ឋាន ជាមួយនឹងភស្តុតាងគាំទ្រមួយចំនួន។[16]

## ២.៣. ខ្លឹមសារនៅក្នុងក្របខ័ណ្ឌច្បាប់កម្ពុជា

មានមាត្រាមួយចំនួនពាក់ព័ន្ធនឹងបញ្ហានេះ ទាំងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣។ មាត្រា ៣២ ចែងថា *ជនគ្រប់រូប...មានសន្តិសុខផ្ទាល់ខ្លួន* ។ មាត្រា ៣៨ ចែង *ច្បាប់ការពារមិនឲ្យមានការរំលោភបំពានលើរូបរាងកាយ ...ការឃាត់ខ្លួន ...នឹងអាចធ្វើទៅកើតលុះត្រាអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។...ការបង្ខិត*

---

*ដល់ខ្សែទី៤ ឬញាតិចំណងអាពាហ៍ពិពាហ៍ខ្សែទី២* (*kin to the fourth level of consanguinity, the second level of affinity [by marriage] or the first civil level*) *របស់ខ្លួនឡើយ*។

[13] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Zimbabwe ឆ្នាំ ២០១៧ ផ្នែក ៥០(៤)។

[14] Jonh B. Traylor, Right to Counsel and Privilege against Self-Incrimination, 2004, p. 196.

[15] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Dominica ឆ្នាំ ២០១៤ ផ្នែក ៨(៧)។

[16] For the specific factors that the European Court says should be taken into account, see: *John Murray v United Kingdom* (18731/91), (1996) §§46-70, *Condron v United Kingdom* (35718/97), (2000) §§55-68, *Heaney and McGuinness v Ireland* (34720/97), (2000) §§55-58, *Funke v France* (10828/84), (1993) §§41-44.

*បង្ខំ ការធ្វើទារុណកម្មលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ។ អ្នកដែលល់...ត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនចាប់ចោទ។*

ផ្អែកលើមូលដ្ឋាននេះ ក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងបន្ថែមផ្តល់សិទ្ធិមានមេធាវី និងជួបមេធាវី[17]៖ *ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិនទៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទីក្នុងលក្ខខណ្ឌទទួលការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនា ជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។*

មានបទបញ្ញត្តិ ទាមទារឲ្យ មន្ត្រីនគរបាលយុត្តិធម៌[18] ព្រះរាជអាជ្ញា[19] និង ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះ ប្រាប់ជនសង្ស័យ ឬជនត្រូវចោទ អំពីសិទ្ធិមានមេធាវី[20]។ បន្ថែមពីលើនេះ មាត្រាបានចែងតម្រូវឲ្យចៅក្រមស៊ើបសួរ ប្រាប់អំពីសិទ្ធិនៅស្ងៀម[21]៖ *នៅពេលចូលបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទប្រាប់ជននេះឱ្យបានដឹងរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលកំណត់ដោយច្បាប់ ។ ចៅក្រមស៊ើបសួរប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬមិនឆ្លើយបានដោយសេរី ។...។*

ជនត្រូវចោទ មិនត្រូវបានតម្រូវឲ្យធ្វើសម្បថទេមុននឹងឆ្លើយ[22]។ ចម្លើយសារភាព នៅក្នុងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវបានសន្មតថា ជាបន្ទាល់ (ខ្លឹមសារដើម) រហូតដល់មានភស្តុតាងផ្ទុយ[23]។ ចៅក្រម ទទួលភស្តុតាងដោយសេរី រួមទាំងចម្លើយសារភាព ដើម្បីយកមកពិនិត្យពិចារណា។[24]

---

[17] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ មាត្រា ៩៨។

[18] ដូចខាងលើ មាត្រា ៩៧។

[19] ដូចខាងលើ មាត្រា ៤៨។

[20] ដូចខាងលើ មាត្រា ១៤៣ និងមាត្រា ៣០៥។

[21] ដូចខាងលើ មាត្រា ១៤៣។

[22] ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Equatorial Guinea ឆ្នាំ ២០១២ មាត្រា ១៣។ច្បាប់រដ្ឋធម្មនុញ្ញប្រទេស Chile ឆ្នាំ ២០១៨ មាត្រា ១៩(១០) ច។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចាត់ថា ប្តីឬប្រពន្ធនៃជនសង្ស័យ ក៏ជាសាក្សីដែរ (មាត្រា ៣២៨) និងរួចផុតពីការធ្វើសម្បថ (មាត្រា ១៥៦)។

មានការយល់ឃើញនៅក្នុងសង្គមជាទូទៅថា កាលណា ជនសង្ស័យមិននិយាយ មិនមានអីដោះសារ ឬ រត់គេច គេយល់ថា គាត់បានប្រព្រឹត្តអំពើល្មើសនោះហើយ។ ប្រសិនបើ គាត់សារភាព គេពិតជាជឿលើចម្លើយសារភាព។ អ្នកនិពន្ធ មិនអាចនិយាយសន្និដ្ឋានជារួម អំពីការយល់ឃើញ ឬសន្និដ្ឋានដូចនេះក្នុងចំណោមមន្ត្រីនៃអង្គតុលាការទេ។ ក៏ប៉ុន្តែ បន្ទាប់ពីបានពិនិត្យមើលសាលក្រមមួយចំនួន មានការកត់សំគាល់ឃើញមានយ៉ាងតិច២ករណី នូវការសន្មតដូចនេះ។[25]

## ២.៤. កំណត់សំគាល់

ការអះអាងថា ចម្លើយត្រូវបានគេបង្ខំ ត្រូវបានលើកនៅក្នុងសវនាការសាលាដំបូង[26]។ ជួនកាលសាលាជាន់ទាប ខកខានមិនបានពិនិត្យ ហើយអះអាងថា ព័ត៌មានរបស់មន្ត្រីនគរបាលយុត្តិធម៌ជាបន្ទាល់រហូតដល់មានភស្តុតាងផ្ទុយ ដែលបន្ទុកភស្តុតាងធ្លាក់ទៅលើ ជនត្រូវចោទ បង្ហាញភស្តុតាង ថាចម្លើយត្រូវបានធ្វើឡើងដោយបង្ខំ។[27] មេធាវី លើកបញ្ហានេះនៅមុខតុលាការកំពូល។ តុលាការកំពូល លើកថា សំអាងហេតុតុលាការជាន់ទាបគ្រប់គ្រាន់ហើយ (មិនចាំបាច់ពិចារណាថា ចម្លើយដោយបង្ខំឬមិនទេ) ហើយ តុលាការកំពូល ពិនិត្យមើលតែបញ្ហាច្បាប់តែប៉ុណ្ណោះ ក្នុងការពិចារណាបណ្តឹងសាទុក្ខលើកទី១។[28]

ទីនេះ បើយើងវិភាគ សូមពិនិត្យមើលរឿងរ៉ាវតាំងពីដំបូង។ ក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឲ្យមានវត្តមានមេធាវីជួបកូនក្តី ក្រោយ ២៤ ម៉ោងកន្លងទៅ បន្ទាប់ពីការឃាត់ខ្លួន។ នោះគឺក្រោយពីមន្ត្រីនគរបាល បានសួរនាំចប់ហើយ ដែលអាចជាការសួរដោយគ្មានវត្តមានរបស់មេធាវី។ ក្នុងអំឡុង ២៤ ម៉ោង

---

[23] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១១០។

[24] ដូចខាងលើ មាត្រា ៣២១៖ លើកលែងបទប្បញ្ញត្តិច្បាប់ផ្ទុយពីនេះ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌអាចជូនបានដោយសេរី ។ តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាងដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ។ ...សារភាពក៏ដូចជាប្រភេទនៃភស្តុតាងដទៃទៀតដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង ។ ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬខាងផ្លូវចិត្តនេះគ្មានតម្លៃជាភស្តុតាងទេ ។...។

[25] *ជនជាប់ចោទឈ្មោះ អ៊ុក ខា បានរត់គេចខ្លួន ដែលជាការគេចវេសពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត*, សាលក្រមព្រហ្មទណ្ឌលេខ ៤២ ជ សាលាដំបូងខេត្តព្រះសីហនុ ចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៧។ សាលាដំបូងរាជធានីភ្នំពេញ សាលក្រមព្រហ្មទណ្ឌលេខ ៤៧១ ចុះថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០១៧ ទំព័រទី៥។

[26] សាលាដំបូងរាជធានីភ្នំពេញ សាលក្រមលេខ ៧១៥ ក្រ១១ ឃ១ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១៨ ទំ.៤។

[27] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១១០។

[28] ដូចខាងលើ មាត្រា ៤៣៦។ ពិនិត្យទាំងអង្គហេតុ និងអង្គច្បាប់ ដោយពេញអង្គក្នុងសាទុក្ខលើកទី២ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤៤២)។

អាចមានរឿងរ៉ាវកើតមានឡើង ស្មានមិនដល់ ដូចជាការគម្រាមឲ្យសារភាពជាដើម។ អ្នកស្រាវជ្រាវ បានរកឃើញថា ការបំពានភាគច្រើន នៅក្នុងអំឡុងពេលនោះ[29]។

ក្រមនីតិវិធីព្រហ្មទណ្ឌ ចែងឲ្យមានបណ្តឹងសុំមោឃៈកិច្ច[30] ហើយមេធាវីអាចលើកបញ្ហានេះនៅមុខចៅក្រម[31]។ អ្វីជាបញ្ហា គឺថាចៅក្រម ទាមទារឲ្យជនត្រូវចោទបង្ហាញភស្តុតាងថា ខ្លួនត្រូវបានគេបង្ខំឲ្យឆ្លើយ។ តាមផ្លូវច្បាប់ ឬយុត្តិសាស្ត្រ បន្ទុកភស្តុតាងត្រូវធ្លាក់លើព្រះរាជអាជ្ញា អះអាងថា ចម្លើយនេះមិនត្រូវបាន ធ្វើឡើងដោយបង្ខំទេ។[32] ប្រសិនបើតុលាការជាន់ទាប ទទួលពិនិត្យ ហើយរកឃើញថា ចម្លើយពិតជាទទួលបានដោយបង្ខំ តាមច្បាប់រដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ នឹងមិនមានតម្លៃជាភស្តុតាងទេ។ តុលាការកំពូល ធ្លាប់អះអាងបញ្ជាក់គាំទ្រយ៉ាងតិច ២ ដង។[33] បើចម្លើយសារភាព ពាក់ព័ន្ធសំខាន់លើភាពមានឬមិនមានទោសពៃរ និងបទមជ្ឈឹម ឬឧក្រិដ្ឋ វាទំនងជាចៅក្រម មិនមានភាពក្លាហានគ្រប់គ្រាន់ក្នុងការបដិសេធ ហើយឲ្យជនសង្ស័យរួចខ្លួនទេ ដោយសារថា ចៅក្រមអាចផ្តល់តម្លៃលើការងាររបស់នគរបាលយុត្តិធម៌ និង ពិបាកទទួលយកនូវការដោះលែងឧក្រិដ្ឋជនណាមួយ ដោយគ្រាន់តែចម្លើយសារភាពដោយបង្ខំតែមួយមុខ។

តាមទ្រឹស្តីនៃការចាប់ផ្តើមជាមួយភាពស្អាតស្អំ (clean hand) មេធាវី គួរត្រូវបានឲ្យចូលរួមពីដំបូងក្នុងអំឡុងពេលដែលនគរបាលយុត្តិធម៌សួរចម្លើយកូនក្តី។ ដើម្បីធ្វើយ៉ាងនេះបាន មាត្រាដែលនិយាយអំពីរយៈពេល ២៤ ម៉ោង គួរត្រូវបានធ្វើវិសោធនកម្ម។ គេគួរកត់សំគាល់ថា ខ្លឹមសារនៃមាត្រា ៩៨នេះត្រូវបានចម្លងពីបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌប្រទេសបារាំង ដែលត្រូវបានកែសម្រួលរួចទៅហើយបន្ទាប់ពីតុលាការសិទ្ធិមនុស្សទ្វីបអឺរ៉ុប រកឃើញថា មាត្រានេះ ផ្ទុយនឹងបទបញ្ញត្តិសិទ្ធិមនុស្ស។ ច្បាប់បារាំងបានអនុញ្ញាតឲ្យមេធាវីជួបកូនក្តីក្នុងដំណាក់កាលដំបូងនៅនគរបាលយុត្តិធម៌ ដែលនេះជាវិធានទូទៅ និង

---

[29] Jacqueline Hodgson, French Criminal Justice: A Comparative Account of the Investigation and Prosecution of Crime in France, 2005, p. 172.

[30] ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ២៥៣។

[31] ដូចខាងលើ មាត្រា ២៥៣។

[32] អវតក អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើភស្តុតាងដែលបានដោយការធ្វើទារុណកម្ម E350/8 ចុះថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៦ កថាខ័ណ្ឌទី ៣៧។ *Deolall v Guyana*, UN Doc. CCPR/C/82/D/912/2000 (2004) §5.1-5.2, *Singarasa v Sri Lanka*, UN Doc. CCPR/C/81/D/1033/2001 (2004) §7.4; See Special Rapporteur on torture, UN Doc. A/61/259 (2006) §65.

[33] មាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃកម្ពុជា។ *ភស្តុតាងជាចម្លើយសារភាពបែបនេះ មិនអាចមានតម្លៃជាភស្តុតាងដាក់បន្ទុកបានឡើយ*, សាលដីកាតុលាការកំពូលលេខ ២៣៩ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០១៣ និង សាលដីកាតុលាការកំពូលលេខ ៣៩ ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩៩។

មានការលើកលែង មិនឲ្យជួប ប្រសិនបើការជួប អាចនាំឲ្យប៉ះពាល់ ឬគ្រោះថ្នាក់ដល់ការស៊ើបអង្កេតនាពេលខាងមុខ (មេធាវីជាក្រុម ឬអ្នកគាំទ្រចលនាបទឧក្រិដ្ឋ ដូចជាភេរវកម្ម)។[34]

ច្បាប់រដ្ឋធម្មនុញ្ញ មាត្រា ៣១ ទទួលស្គាល់សន្ធិសញ្ញាសិទ្ធិមនុស្ស។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ ២០០៧ ចាត់សន្ធិសញ្ញាជាច្បាប់ ដែលតុលាការ ត្រូវប្រើប្រាស់ដើម្បីបកស្រាយ។[35] ដូចបានអះអាងខាងលើ ច្បាប់រដ្ឋធម្មនុញ្ញជាច្រើន ចែងផ្ទាល់នូវបទប្បញ្ញត្តិ ពាក់ព័ន្ធសិទ្ធិមិនត្រូវបានបង្ខំឲ្យឆ្លើយដាក់បន្ទុក ដោយគ្មានលើកលែង អាស្រ័យហេតុនេះ គេអាចអះអាងបានថា មិនចាំបាច់ កែប្រែមាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ពីព្រោះ វាត្រូវចំណាយពេលវេលាយូរ។ ការអនុវត្តសិទ្ធិនេះ ដោយផ្ទាល់ ពិតជាអាចជួយបាន និងមិនខុសនឹងច្បាប់រដ្ឋធម្មនុញ្ញទេ។ បន្ថែមពីលើនេះ តុលាការកំពូល ឬក្រសួងយុត្តិធម៌ អនុលោមតាមច្បាប់រដ្ឋធម្មនុញ្ញ ឬខ្លឹមសារនៃសេចក្តីរបស់ក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំ ២០០៧ អាចធ្វើសេចក្តីណែនាំអនុវត្ត ដូចដែលខ្លួនធ្លាប់ធ្វើ ពាក់ព័ន្ធមាត្រា ៦៣ (បទបរិហាកេរ្តិ៍) នៃច្បាប់ព្រហ្មទណ្ឌឆ្នាំ ១៩៩៣។[36]

## ៣. ខ្លឹមសារសង្ខេប

សិទ្ធិមិនត្រូវបង្ខំឲ្យឆ្លើយដាក់បន្ទុក និងមិនឆ្លើយ មានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលរដ្ឋជាភាគី ច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ដទៃទៀត ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌ ទោះបីមិនបានចែងចំជាក់លាក់ និងលម្អិតក្តី។ មូលហេតុនៃអត្ថិភាពនៃសិទ្ធិនេះ គឺមានសារៈសំខាន់ក្នុងនីតិវិធីក្តីព្រហ្មទណ្ឌតាំងពីដំណាក់កាលដំបូងនៃស៊ើបអង្កេតដោយនគរបាលយុត្តិធម៌។ ការគោរពសិទ្ធិនេះ នឹងនាំមិនឲ្យមានការបំពាន ដែលពេលក្រោយមក លទ្ធផលនៃការសើបអង្កេត ឬភស្តុតាង អាចនឹងត្រូវបានបដិសេធដោយតុលាការ។ ក្នុងន័យនេះ វាចាំបាច់តម្រូវឲ្យមានការទទួលស្គាល់ និងការគោរពសិទ្ធិនេះ ដោយយោងដល់បទប្បញ្ញត្តិអន្តរជាតិ ដើម្បីបំពេញបន្ថែមក្នុងពេលបទប្បញ្ញត្តិច្បាប់ជាតិ មានន័យមិនគ្រប់គ្រាន់។

---

34 រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី ការឃុំខ្លួននៅស្ថានីយ៍ប៉ូលីស ដែលត្រូវបានដាក់ជូនដល់ក្រុមប្រឹក្សារដ្ឋមន្ត្រី ក្នុងថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១០។ សេចក្តីព្រាង អនុញ្ញាតនូវវត្តមានមេធាវី ក្នុងគ្រប់ដំណាក់កាលនៃការឃុំខ្លួនដោយប៉ូលីស ជាមួយការលើកលែងផងដែរ(Premier Ministre, Projet de loi relative au recours à la garde à vue, government official website (Oct. 14, 2010),French criminal procedure, European Court of Human Rights; France: Rights to Remain Silent and to Be Assisted by a Lawyer | Global Legal Monitor (loc.gov)

35 សេចក្តីម្រេចក្រុមប្រឹក្សាធម្មនុញ្ញ លេខ០៩២/០០៣/២០០៧/កបធ.ច ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧។

36 សេចក្តីណែនាំរួម របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងប្រធានតុលាការកំពូល អំពីការអនុវត្តន៍ច្បាប់ស្តីពីបទល្មើសបរិហាកេរ្តិ៍ក្នុងមាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល, ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជាកម្រងឯកសារច្បាប់ ឆ្នាំ ២០០៩ ទំព័រ ១០៦១-១០៦២។